00350433

**Declassified to Public**
**06 September 2012**

E27/3/1

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងព្រហ្មទណ្ឌលេខ៖** ០០១/១៨-០៧-២០០៧-**អវតក/អជសដ**

**ដាក់តម្កល់ជូន៖** អង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទដាក់ឯកសារ៖** ១៣/០៧/០៩

**ភាគីអ្នកតម្កល់៖** សហមេធាវីការពារក្តីលោក កាំង ហ្កេកអ៊ាវ

**ភាសាដើម៖** បារាំង

**ប្រភេទឯកសារ៖** សម្ងាត់បំផុត

---

## ចំណាររបស់សហមេធាវីការពារក្តីចំពោះសេចក្តីសន្និដ្ឋានលើរបាយការណ៍វាយតម្លៃផ្នែកចិត្តសាស្ត្ររបស់លោកសាស្ត្រាចារ្យ កា ស៊ុនបូណាត ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩

---

**អ្នកដាក់តម្កល់:**

**សហមេធាវីជនជាប់ចោទ**

**កាំង ហ្កេកអ៊ាវ ហៅ ឌុច**

មេធាវី **ការ សាវុត្ថ**

មេធាវី **François ROUX**

**តម្កល់ជូន:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម **និល ណុន** ជាប្រធាន

លោកស្រីចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **ធូ មណី**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / JUL / 2009
ម៉ោង (Time/Heure): 08 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E24/3/L

[០០១/១៨-០៧-២០០៧-អវតក/អជសង]

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ សហមេធាវីការពារក្តីបានដាក់នូវសំណើសុំឱ្យមានការតែងតាំងអ្នកឯកទេសខាងចិត្តវិទ្យាម្នាក់ ដើម្បីផ្តល់ការគាំពារដល់លោក **កាំង ហ្កេកអ៊ាវ** នៅក្នុងអំឡុងពេលនៃសវនាការ។ កាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងលោកសាស្ត្រាចារ្យ ការ ស៊ុនបូណាត ដើម្បីឱ្យលោកធ្វើការសិក្សាថា តើគួរមានការគាំពារផ្នែកផ្លូវចិត្តណាមួយត្រូវផ្តល់ជូនជនជាប់ចោទដែរឬទេ។ យោងលើរបាយការណ៍ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ជនជាប់ចោទមិនបានបង្ហាញនូវសញ្ញាណនៃភាពតានតឹងផ្នែកសតិអារម្មណ៍ណាមួយដែលគួរតម្រូវឱ្យមានការគាំពារផ្លូវចិត្តនោះទេ។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងតាមរយៈលិខិតជាលាយលក្ខអក្សរចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ មកសហមេធាវីការពារក្តី ដើម្បីសុំឱ្យសហមេធាវីការពារក្តីបញ្ជាក់ពីជំហររបស់ខ្លួនចំពោះបញ្ហានេះ។

២. សហមេធាវីការពារក្តីបានលើកឡើងពីខាងដើមថា អង្គជំនុំជម្រះសាលាដំបូងបានដាក់កម្រិតឱ្យសហមេធាវីការពារត្រូវដាក់ចម្លើយតបរបស់ខ្លួនឱ្យបានមុនថ្ងៃច័ន្ទ ទី៦ ខែ កក្កដា ឆ្នាំ ២០០៩។ ក៏ប៉ុន្តែ សហមេធាវីការពារក្តីទើបនឹងបានទទួលសេចក្តីជូនដំណឹងឱ្យដាក់ចម្លើយតបជាភាសាខ្មែរ និងជាភាសាបារាំងនេះ កាលពីថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ ប៉ុណ្ណោះ។ ដូច្នេះសហមេធាវីការពារក្តីមិនមានលទ្ធភាពក្នុងការផ្តល់ចម្លើយតបក្នុងពេលវេលាដែលបានកំណត់ខាងលើឡើយ ដោយមូលហេតុពេលវេលាដែលផ្តល់ជូនមានរយៈពេលខ្លីពេក។ ម្យ៉ាងទៀត ទោះបីជាសហមេធាវីការពារក្តីបានទទួលរបាយការណ៍វាយតម្លៃផ្នែកចិត្តសាស្ត្រជាភាសាខ្មែរ តាំងពីថ្ងៃទី ៣ ខែ កក្កដា ក៏ដោយ ក៏សហមេធាវីទើបនឹងទទួលបានរបាយការណ៍នេះជាភាសាបារាំង នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ នេះប៉ុណ្ណោះ។ ដូច្នេះសហមេធាវីការពារក្តីសូមស្នើទៅអង្គជំនុំជម្រះសាលាដំបូង មេត្តាយោគយល់ពីបញ្ហានេះ និងមេត្តាទទួលយកការដាក់ចម្លើយតបដែលនឹងមានការយឺតយ៉ាវ ដោយអនុគ្រោះ។

៣. សហមេធាវីការពារក្តីបានកត់សម្គាល់ឃើញថា របាយការណ៍វាយតម្លៃផ្នែកចិត្តសាស្ត្រត្រូវបានធ្វើកាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩។ ជាក់ស្តែង តាំងពីថ្ងៃនោះមក លោក **កាំង ហ្គេកអ៊ាវ** បានបង្ហាញនូវសញ្ញាណនៃការប៉ះទង្គិចផ្នែកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរនៅក្នុងអង្គសវនាការ។ យោងលើស្ថានភាពនេះ មេធាវីការពារក្តីសូមរក្សាជំហរក្នុងការស្នើសុំឱ្យមានកិច្ចគាំពារផ្នែកផ្លូវចិត្តជូនលោក **កាំង ហ្គេកអ៊ាវ** ហើយសូមស្នើឱ្យអង្គជំនុំជម្រះមេត្តាចាត់ឱ្យមានអ្នកឯកទេសចិត្តសាស្ត្រម្នាក់ ដើម្បីផ្តល់នូវការគាំពារដោយផ្ទាល់ដល់ជនជាប់ចោទនៅក្នុងដំណាក់កាលនៃសវនាការ ឬយ៉ាងហោចណាស់បានជួបជនជាប់ចោទមួយដងដែរក្នុងរវាងដប់ប្រាំថ្ងៃម្តង។

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| សហមេធាវីទាំងពីរ<br><br>មេធាវី **កាត សាវុត្ថ**<br><br>មេធាវី **François ROUX** | ភ្នំពេញ | |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |